**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៣៥៦៤/២២ មស.សជណ

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងមុខងារសាធារណៈ ក៏ដូចជាសាធារណជន មេត្តាជ្រាបថា៖ សាលាភូមិន្ទរដ្ឋបាល នៃក្រសួងមុខងារសាធារណៈ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិផ្តល់ឈាមនឹងរៀបចំ **«កម្មវិធីបរិច្ចាគឈាមដើម្បីសង្គ្រោះជីវិត»** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២** ចាប់ពីវេលាម៉ោង **៧៖៣០នាទីព្រឹក** នៅសាលាភូមិន្ទរដ្ឋបាល។

កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីរួមចំណែកក្នុងការជួយដល់ជនរងគ្រោះ ដែលមានតម្រូវការឈាមដើម្បីសង្គ្រោះបន្ទាន់។

ក្នុងន័យនេះក្រសួង សូមអំពាវនាវ និងគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងបងប្អូនសាធារណជន មេត្តាចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្តរៀងៗខ្លួន តាមកាលបរិច្ឆេទដូចបានជម្រាបជូនខាងលើ ក្នុងស្មារតីមនុស្សធម៌ សង្គហធម៌ដ៏ប្រពៃជ្រាលជ្រៅ ដើម្បីរួមចំណែកជួយសង្គ្រោះជីវិតប្រជាពលរដ្ឋដែលមានតម្រូវការឈាមចាំបាច់។

សូមគោរពជម្រាបផងដែរថា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនសាធារណជន អាចចុះឈ្មោះជាមុនតាមរយៈតំណភ្ជាប់ https://bit.ly/3Pvkj5H ឬតាម QR code ដូចមានជូនភ្ជាប់។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៣ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២




**សូមទំនាក់ទំនងសម្រាប់ព័ត៌មានលម្អិត៖**
- លោក ណុច រ៉ាម៉ូ (០៦១ ៦៦៥ ៧២២)
- លោក ស៊ឹម វ៉េងហេង (០៦៩ ៥៧៣ ០៣៩)